# បានចងភ្ជាប់ទៅនឹងព្រះអង្គសង្គ្រោះតាមរយៈសេចក្ដីសញ្ញា និងពិធីបរិសុទ្ធ



គម្រោងមេរៀនបំពាក់បំប៉នសម្រាប់តំបន់ សម្រាប់ការសម្របសម្រួលក្នុងក្រុមប្រឹក្សាបេសកកម្ម ស្តេក វួដ និងសាខា

*ក្នុងអំឡុងពេលនៃការណែនាំនេះ អ្នកនឹងឃើញ ព្រមទាំងស្ដាប់ឮនូវបទពិសោធន៍របស់បុត្រាបុត្រីនៃព្រះវរបិតាសួគ៌យើងនៅតាមដំណាក់កាលខុសៗគ្នា នៅលើមាគ៌ានៃការបានចងភ្ជាប់ទៅនឹងព្រះអង្គសង្គ្រោះតាមរយៈសេចក្ដីសញ្ញា និងពិធីបរិសុទ្ធ។ អ្នកនឹងស្ដាប់ឮពីរបៀបដែល ការស្រឡាញ់ ការចែកចាយ និងការអញ្ជើញ បានជួយពួកគេឲ្យរីកចម្រើននៅលើមាគ៌ានៃសេចក្ដីសញ្ញាដោយមានអំណរ។ អ្នកអាចស្គាល់ពីរបៀបដែលការចែកចាយដំណឹងល្អ កិច្ចការព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ ព្រមទាំងការថែទាំដល់ជនទ័លក្រទាំងអស់នេះសុទ្ធតែបានចូលរួមចំណែកជួយ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ គឺអ្នកអាចកត់សម្គាល់ពីរបៀបដែលកិច្ចការទាំងអស់នេះ « [ បាន ] បំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ ... » ( អេភេសូរ ១:១០ )។*

## ដំណាក់កាលជីវិតទី ១៖ កុមារ



សូមមើល **វីដេអូដែលមានប្រធាន ចយ ឌី ចូនស៍ ជាមួយនឹងកុមារ** រួចហើយសូមពិភាក្សាពីអ្វីដែលអ្នកនឹងទៅ ហើយធ្វើ ដើម្បីជួយកុមារឲ្យចងភ្ជាប់ខ្លួនពួកគេទៅនឹងព្រះអង្គសង្គ្រោះនៅលើមាគ៌ានៃសេចក្ដីសញ្ញានេះ។

- តើព្រះវិញ្ញាណបានបង្រៀនយើងអ្វីខ្លះ នៅពេលយើងបានមើលវីដេអូនេះ ?
- តើគោលការណ៍នៃការស្រឡាញ់ ការចែកចាយ និងការអញ្ជើញនេះ ជួយកុមារតាមរបៀបណា នៅពេលដែលពួកគេព្យាយាមចែកចាយដំណឹងល្អនោះ ?
- តើការបម្រើជួយកុមារឲ្យបន្តនៅលើមាគ៌ានៃសេចក្ដីសញ្ញា បន្ទាប់ពីពិធីបុណ្យជ្រមុជទឹកដោយរបៀបណា ?

## ដំណាក់កាលជីវិតទី ២៖ យុវវ័យ

សូមមើល **វីដេអូដែលមានប្រធាន ប៊ូនី អេច ខ័រឌុន និងប្រធាន ស្ទេវីន ជេ ឡាន់ ជាមួយនឹងយុវវ័យ** រួចហើយសូមពិភាក្សាពីអ្វីដែលអ្នកនឹងទៅ ហើយធ្វើ ដើម្បីជួយយុវវ័យឲ្យចងភ្ជាប់ខ្លួនពួកគេទៅនឹងព្រះអង្គសង្គ្រោះនៅលើមាគ៌ានៃសេចក្ដីសញ្ញានេះ។

- តើយើងអាចជួយយុវវ័យឲ្យរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ពួកគេ ហើយរៀបចំខ្លួនសម្រាប់ជំហានបន្ទាប់នៅតាមមាគ៌ានៃសេចក្ដីសញ្ញានេះដោយរបៀបណា ?
- តើគោលការណ៍នៃការស្រឡាញ់ ការចែកចាយ និងការអញ្ជើញនេះ ជួយយុវវ័យឲ្យចូលរួមក្នុងកិច្ចការព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិតាមរបៀបណា ?
- តើយើងអាចជួយយុវវ័យឲ្យមានសេចក្ដីសង្ឃឹម និងអារម្មណ៍ជាកម្មសិទ្ធិ នៅពេលពួកគេបានចងភ្ជាប់ទៅនឹងព្រះអង្គសង្គ្រោះយ៉ាងដូចម្ដេច ?

## ដំណាក់កាលជីវិតទី ៣៖ យុវមជ្ឈិមវ័យ

សូមមើល **វីដេអូដែលមានប្រធាន ម៉ាក អិល ផេស ជាមួយនឹងយុវមជ្ឈិមវ័យ** រួចហើយសូមពិភាក្សាពីអ្វីដែលអ្នកនឹងទៅ ហើយធ្វើ ដើម្បីជួយយុវមជ្ឈិមវ័យឲ្យចងភ្ជាប់ខ្លួនពួកគេទៅនឹងព្រះអង្គសង្គ្រោះនៅលើមាគ៌ានៃសេចក្ដីសញ្ញានេះ។

- តើយើងរៀនអ្វីខ្លះមកពីការស្រឡាញ់ ការចែកចាយ និងការអញ្ជើញដែលមនុស្សដទៃបានផ្តល់មកកាន់យើង ?
- តើយើងអាចជួយយុវមជ្ឈិមវ័យឲ្យមានសេចក្ដីសង្ឃឹម និងអារម្មណ៍ជាកម្មសិទ្ធិ នៅពេលពួកគេបង្កើនភាពខ្លួនទីពឹងខ្លួន និងការបម្រើដល់មនុស្សដទៃយ៉ាងដូចម្ដេច ? តើយើងអាចជួយពួកគេឲ្យដឹងថា យើងត្រូវការពួកគេនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់តាមរបៀបណា ?
- តើសកម្មភាពក្នុងសាសនាចក្រដ៏មានអត្ថន័យ និងថ្នាក់ដឹកនាំដែលយកចិត្តទុកដាក់ ដើរតួនាទីអ្វីខ្លះនៅក្នុងការចងភ្ជាប់យុវមជ្ឈិមវ័យទៅនឹងព្រះអង្គសង្គ្រោះ ?

### ដំណាក់កាលជីវិតទី ៤៖ មជ្ឈិមវ័យ

សូមមើល **វីដេអូដែលមានប្រធាន ជីន ប៊ី ប៊ីងហាំ ជាមួយនឹងមជ្ឈិមវ័យ** រួចហើយសូមពិភាក្សាពីអ្វីដែលអ្នកនឹងទៅ ហើយធ្វើ ដើម្បីជួយមជ្ឈិមវ័យឲ្យចងភ្ជាប់ខ្លួនពួកគេទៅនឹងព្រះអង្គសង្គ្រោះនៅលើមាគ៌ានៃសេចក្តីសញ្ញានេះ។

- តើសេចក្តីសញ្ញារបស់យើងនាំឲ្យមានការព្យាបាល ហើយជួយយើងឲ្យបន្តនៅលើមាគ៌ានេះដោយរបៀបណា—ទោះបីជាយើងស្ថិតក្នុងគ្រាដ៏លំបាកយ៉ាងណាក្តី ?
- តើយើងរកឃើញរបៀបអ្វីខ្លះ ដើម្បីជួយសមាជិកឲ្យចងភ្ជាប់ខ្លួនរបស់ពួកគេ និងមនុស្សដទៃទៀត ទៅនឹងព្រះអង្គសង្គ្រោះតាមរយៈសេចក្តីសញ្ញា និងពិធីបរិសុទ្ធ ?
- តើការអភិវឌ្ឍភាពខ្លួនទីពឹងខ្លួនខាងវិញ្ញាណជួយយើងឲ្យចេះស្រឡាញ់ ចែកចាយ និងអញ្ជើញតាមរបៀបណា ?

ធនធានទាំងឡាយសម្រាប់តំបន់ សម្រាប់ការសម្របសម្រួលក្នុងក្រុមប្រឹក្សាបេសកកម្ម ស្តេក វួដ និងសាខា

# សម្រាប់កុមារ និងយុវវ័យ

## ទិដ្ឋភាពទូទៅស្តីពីកម្មវិធីកុមារ និងយុវវ័យ



*កម្មវិធីកុមារ និងយុវវ័យត្រូវបានរៀបចំឡើងដើម្បីពង្រឹងសេចក្តីជំនឿរបស់ជំនាន់កំពុងពេញវ័យទៅលើព្រះយេស៊ូវគ្រីស្ទ ហើយជួយកុមារ យុវវ័យ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេឲ្យរីកចម្រើននៅលើមាគ៌ានៃសេចក្តីសញ្ញា នៅពេលពួកគេជួបនឹងឧបសគ្គក្នុងជីវិត។ វាជួយកុមារ និងយុវវ័យក្នុងកិច្ចខិតខំរបស់ពួកគេដើម្បីចូលរួមក្នុងការប្រមូលផ្តុំអ៊ីស្រាអែល ព្រមទាំងកិច្ចការនៃសេចក្តីសង្គ្រោះ និងការលើកតម្កើងឡើងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ កម្មវិធីនេះផ្តោតសំខាន់នៅក្នុងគេហដ្ឋាន និងមានជំនួយពីព្រះវិហារ។*

### សេចក្តីសង្ឃឹមសម្រាប់ជំនាន់កំពុងពេញវ័យ

កម្មវិធីកុមារ និងយុវវ័យជួយជំនាន់កំពុងពេញវ័យឲ្យរីកចម្រើនឡើងតាមរបៀបជាច្រើន រួមមានតាមរយៈវិវរណៈ សិទ្ធិជ្រើសរើស និងទំនាក់ទំនង។ បុគ្គលម្នាក់ៗរៀនទទួល និងធ្វើសកម្មភាពតាមវិវរណៈផ្ទាល់ខ្លួន កាលពួកគេអនុវត្តសិទ្ធិជ្រើសរើស និងរើសយកឱកាសដើម្បីអភិវឌ្ឍខ្លួនគេ។ ការណ៍នេះក៏កើតឡើងផងដែរ នៅពេលយុវវ័យរៀនដឹកនាំនៅក្នុងគណៈប្រធានកូរ៉ុម និងថ្នាក់រៀន។ ពួកគេបង្កើតទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ពួកគេ ថ្នាក់ដឹកនាំរបស់ពួកគេ និងមនុស្សដទៃទៀតដែលមានអាយុស្រាបាលនឹងពួកគេ កាលដែលពួកគេធ្វើការ និងបម្រើរួមគ្នា ហើយដឹងថា ពួកគេមានចំណែកកម្មសិទ្ធិ និងត្រូវការជាចាំបាច់នៅក្នុងកិច្ចការរបស់ព្រះអម្ចាស់។

## តើយើងគួរតែចាប់ផ្ដើមត្រង់ណានៅថ្ងៃនេះ ?

យើងសូមអញ្ជើញកុមារ យុវវ័យ និងឪពុកម្ដាយ ព្រមទាំងថ្នាក់ដឹកនាំរបស់ពួកគេឲ្យប្ដេជ្ញាចិត្ត ឬតាំងចិត្តសាជាថ្មីឡើងវិញដើម្បីក្លាយឲ្យកាន់តែដូចជាព្រះអង្គសង្គ្រោះតាមរយៈ ការចូលរួមក្នុងកិច្ចការរបស់ទ្រង់ ។ កិច្ចខិតខំទាំងនេះមិនចាំបាច់ពិបាកពេកនោះទេ ! ទាំងនេះជាចំណុចសាមញ្ញៗមួយចំនួនដើម្បីចាប់ផ្ដើម ៖

### ឪពុកម្ដាយ

- សូមប្រមូលគ្រួសាររបស់អ្នកឲ្យមកសិក្សាដំណឹងល្អ ។ ធនធាន *ចូរមកតាមខ្ញុំ* អាចជួយបាន ។ អ្នកអាចពិចារណាដល់ការពិភាក្សាគ្នាអំពីប្រធានបទនានាដូចជា សេចក្ដីសញ្ញា វិវរណៈ សិទ្ធិជ្រើសរើស និងពរជ័យលោកអយ្យកោ ។
- សូមដាក់ផែនការធ្វើសកម្មភាពជាគ្រួសារមួយ ។ តើអ្នកអាចបម្រើដល់នរណាម្នាក់នៅក្នុងភូមិ ឬសហគមន៍របស់អ្នកប្រកបដោយសុវត្ថិភាពយ៉ាងដូចម្ដេច ? នៅកន្លែងណាដែលមាន គេហទំព័រ JustServe អាចជួយអ្នកឲ្យស្វែងរកគំនិតនានាបាន ។
- សូមជួបមួយទល់មួយជាមួយនឹងកូនប្រុស និងកូនស្រីម្នាក់ៗ ។ សូមពិភាក្សាពីចំណាប់អារម្មណ៍របស់ពួកគេ ហើយជជែកពីរបៀបដែលពួកគេចង់រីកចម្រើនឡើង ។ សូមជួយ ហើយគាំទ្រដល់ការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមនិយាយអំពីគោលដៅណា ដែលពួកគេបានដាក់ ឬចង់សម្រេចគោលដៅនោះ ។

### ថ្នាក់ដឹកនាំអង្គការបឋមសិក្សា

- សូមដឹងពីស្ថានភាពក្នុងគេហដ្ឋានរបស់កុមារ ហើយស្វែងរកវិវរណៈដើម្បីជួយពួកគេជាលក្ខណៈបុគ្គល ។
- សូមចាប់ផ្ដើមធ្វើការប្រជុំថ្ងៃអាទិត្យ និងសកម្មភាពអង្គការបឋមសិក្សាជាលក្ខណៈដោយផ្ទាល់ ឬតាមអនឡាញ ( នៅពេលដែលមានសុវត្ថិភាព និងមានការអនុញ្ញាត ) ។
- សូមកុំបារម្ភពីការភ្ជាប់គោលដៅរបស់បុគ្គលម្នាក់ៗទៅនឹងសកម្មភាពឡើយ ! សូមអ្នកផ្ដោតលើការទាក់ទងនឹងមនុស្ស ព្រមទាំងការផ្ដល់ពរជ័យដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេ—ជាពិសេសនៅពេលពួកគេត្រូវការ ឬសូមជំនួយ ។

### ថ្នាក់ដឹកនាំមជ្ឈិមវ័យលើយុវវ័យ

- សូមចាប់ផ្ដើមធ្វើការប្រជុំថ្ងៃអាទិត្យ និងសកម្មភាពកូរ៉ុម និងថ្នាក់រៀនជាលក្ខណៈដោយផ្ទាល់ ឬតាមអនឡាញ ( នៅពេលដែលមានសុវត្ថិភាព និងមានការអនុញ្ញាត ) ។ សូមលើកទឹកចិត្តយុវវ័យឲ្យទន្ទេញចាំ និងចាប់ផ្ដើមការប្រជុំដោយមានបាវចនាយុវនារីថ្មី និងកូរ៉ុមបព្វជិតភាពអើរ៉ុន ។
- សូមហៅបម្រើ ញែកចេញ និងពង្រឹងដល់គណៈប្រធានកូរ៉ុម និងថ្នាក់ទាំងឡាយ ។ សូមជួយពួកគេឲ្យធ្វើការប្រជុំគណៈប្រធានជាទៀងទាត់ ហើយដាក់ផែនការ ព្រមទាំងដឹកនាំការប្រជុំនៅថ្ងៃអាទិត្យ និងសកម្មភាពនានា ។ សូមធ្វើការប្រជុំក្រុមប្រឹក្សាយុវវ័យវួដ និងលើកទឹកចិត្តឲ្យមានការចូលរួមនៅក្នុងការប្រជុំសម្របសម្រួលកិច្ចការផ្សព្វផ្សាយសាសនា ព្រមទាំងកិច្ចការព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ ។ សូមបង្វឹក និងគាំទ្រដល់គណៈប្រធានទាំងឡាយតាមការចាំបាច់ ដោយមិនធ្វើជំនួសពួកគេ ។ សូមជួយគណៈប្រធានទាំងឡាយឲ្យរៀនជំនាញភាពជាអ្នកដឹកនាំ ដោយប្រើ ធនធានគណៈប្រធានកូរ៉ុម និងថ្នាក់ ។
- សូមដាក់ផែនការ និងធ្វើការបោះជំរុំយុវវ័យ និងសន្និសីទយុវវ័យនៅឆ្នាំ ២០២១ ដោយធ្វើតាមគោលការណ៍ណែនាំស្ដីពីសុវត្ថិភាព ។
- សូមកុំបារម្ភពីការភ្ជាប់គោលដៅរបស់បុគ្គលម្នាក់ៗទៅនឹងសកម្មភាពឡើយ ! សូមដាក់ថាមពលរបស់អ្នកទៅលើការទាក់ទងជាមួយនឹងយុវវ័យដោយផ្ទាល់វិញ ។ អ្នកក៏អាចជួយដល់គណៈប្រធានកូរ៉ុម និងថ្នាក់ទាំងឡាយ ឲ្យភ្ជាប់សកម្មភាពនានាទៅនឹងតម្រូវការរបស់យុវវ័យផងដែរ ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ **CHILDRENANDYOUTH.CHURCHOFJESUSCHRIST.ORG** ។

# សម្រាប់មជ្ឈិមវ័យ

## ទីតាំងប្រមូលផ្តុំ យ.ម.ល.

គណៈប្រធានទីមួយបានផ្តល់ការអនុម័តលើតំបន់ជាច្រើន ដើម្បីបង្កើតជាទីតាំងប្រមូលផ្តុំយុវមជ្ឈិមវ័យនៅលីវ ដោយផ្អែកទៅលើតម្រូវការតាមតំបន់។ ទីតាំងប្រមូលផ្តុំគឺជាទីតាំងដែលបានរៀបចំទុកមួយនៅក្នុងអគារដែលមានស្រាប់ ( ដូចជា សាលាប្រជុំ ឬអគារថ្នាក់វិទ្យាស្ថាន ) ជាកន្លែងដែលយុវមជ្ឈិមវ័យនៅលីវ និងមិត្តភក្តិរបស់ពួកគេអាចជួបជុំគ្នាដើម្បីចូលរួមក្នុងសកម្មភាពដូចខាងក្រោមនេះមួយចំនួន ឬទាំងអស់ ( ដោយផ្អែកទៅលើតម្រូវការ និងធនធានក្នុងមូលដ្ឋាន )៖

- ការអប់រំខាងសាសនា និងការរៀនសូត្រដំណឹងល្អ ( រួមមានថ្នាក់វិទ្យាស្ថានផងដែរ )
- ការបម្រើ និងសកម្មភាពសង្គមនានា
- សកម្មភាពកិច្ចការព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ
- ឱកាសសម្រាប់ភាពខ្លួនទីពឹងខ្លួន និងការអប់រំ
- សកម្មភាពផ្សព្វផ្សាយសាសនា និងការជួយក្នុងសហគមន៍
- កម្មវិធីសាសនាចក្រផ្សេងៗទៀត



ទីតាំងប្រមូលផ្តុំទាំងអស់ត្រូវតែទទួលបានការអនុម័តពីគណៈប្រធានតំបន់ និងមានការមើលខុសត្រូវដោយ ប្រធានស្តេក និងប៊ីស្សព។

### ការហៅបម្រើសម្រាប់យុវមជ្ឈិមវ័យនៅលីវ និងមជ្ឈិមវ័យនៅលីវ

ការផ្លាស់ប្តូរគោលនយោបាយ និងការបញ្ជាក់នាពេលថ្មីៗនេះបានដោះស្រាយនូវការយល់ខុស និងប្រពៃណីខុសឆ្គងដែលអាចកើតមាននានាស្តីពីការដាក់កម្រិតទៅលើ ឱកាសសម្រាប់សមាជិកនៅលីវដើម្បីធ្វើការបម្រើក្នុងសាសនាចក្ររបស់ព្រះអម្ចាស់។ ការផ្លាស់ប្តូរគោលនយោបាយ និងការបញ្ជាក់ទាំងនេះ ដែលមានការអនុម័តពីគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកដប់ពីរនាក់ ព្រមទាំងបានដាក់បញ្ចូលនៅក្នុងសៀវភៅ *ក្បួនខ្នាតទូទៅ* ពន្យល់ថា យុវមជ្ឈិមវ័យនៅលីវ និងមជ្ឈិមវ័យនៅលីវអាចទទួលបានពរជ័យដោយសារមនុស្សដទៃទៀត ហើយអាចផ្តល់ពរជ័យដល់មនុស្សដទៃទៀតនៅក្នុងការហៅបម្រើជាច្រើន រួមមានដូចជាថ្នាក់ដឹកនាំស្តេក និងវួដជាដើម។ ឥឡូវនេះ គោលនយោបាយដូចគ្នានេះមានសុពលភាពសម្រាប់អង្គភាពសាសនាចក្រទាំងអស់ រួមទាំងអង្គភាពយុវមជ្ឈិមវ័យនៅលីវ និងមជ្ឈិមវ័យនៅលីវផងដែរ។ ការដាក់កំហិតលើយុវមជ្ឈិមវ័យនៅលីវ និងមជ្ឈិមវ័យនៅលីវមិនឲ្យធ្វើការបម្រើក្នុងគណៈប្រធានស្តេក គណៈប៊ីស្សព និងគណៈប្រធានសមាគមសង្គ្រោះស្តេកនៅក្នុងអង្គភាពយុវមជ្ឈិមវ័យនៅលីវ និងមជ្ឈិមវ័យនៅលីវត្រូវបានដកចេញ។

សមាជិកនៅលីវទាំងឡាយអាចបម្រើក្នុងតួនាទីជាអ្នកដឹកនាំបាន រួមមានគណៈប្រធានអង្គការក្នុងវួដ និងស្តេក គណៈប្រធានកូរ៉ុមអែលឌើរ ទីប្រឹក្សាគណៈប៊ីស្សព ទីប្រឹក្សាជាន់ខ្ពស់ និងទីប្រឹក្សាគណៈប្រធានស្តេក។

# ការត្រូវការ និងការស្វាគមន៍ដល់មនុស្សទាំងអស់—ស្រឡាញ់ ចែកចាយ និងអញ្ជើញ

នៅពេលសមាជិកពិបាកនឹងមានអារម្មណ៍ថាចុះចំណោមនឹងគេ ពេលខ្លះថ្នាក់ដឹកនាំ និងមនុស្សដទៃទៀតក៏និយាយអ្វីដោយអចេតនាដែល ពង្រឹងដល់ជំនឿរបស់សមាជិកទាំងនេះថា ពួកគេចូលមិនចុះនឹងគេ ឬថាមិនមានអ្នកត្រូវការពួកគេនោះទេ។

ការចងចាំដល់សេចក្តីពិតទាំងនេះអំពីការស្រឡាញ់ ការចែកចាយ និងការអញ្ជើញអាចជួយនៅក្នុងការស្វាគមន៍មនុស្សទាំងអស់ឲ្យមកកាន់សកម្មភាព មិត្តភាព និងការរាប់អាននៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទបាន ៖



- មនុស្សគ្រប់រូបគឺជាបុត្រសំណព្វរបស់ព្រះ ដែលមាននិស្ស័យ និងជោគវាសនាដ៏ទេវភាពមួយ ។ បន្ថែមពីលើពរជ័យដ៏អស់កល្បជានិច្ច នោះទ្រង់សន្យាដល់អ្នកដែលស្មោះត្រង់ថា ទ្រង់សព្វព្រះទ័យប្រទានពរដល់បុត្រាបុត្រីរបស់ទ្រង់នាពេលនេះ អំឡុងជីវិតនេះ ។
- បុត្រម្នាក់ៗរបស់ព្រះគឺចាំបាច់នៅក្នុងកិច្ចការនៃការស្ថាបនានគររបស់ទ្រង់ ។
- ដើម្បីជួយនរណាម្នាក់ឲ្យមានអារម្មណ៍ថា គាត់ ឬនាងគឺជាចំណែកកម្មសិទ្ធិ និងចាំបាច់នោះ សូមចាប់ផ្តើមដោយការស្រឡាញ់ ។ សូមស្តាប់ដើម្បីយល់ពីបទពិសោធន៍របស់ពួកគាត់ ។ សូមកុំស្មានថា អ្នកដឹង ឬយល់រួចហើយនោះ ។
- យើងមិនមានចម្លើយចំពោះសំណួរទាំងអស់ដែលយើង ឬមនុស្សដទៃមាននៅក្នុងជីវិតនេះនោះទេ ។ ឧទាហរណ៍ យើងមិនដឹងពីមូលហេតុដែលបុគ្គលម្នាក់កំពុងតែប្រឈមមុខនឹងឧបសគ្គជាក់លាក់មួយទេ ។
- សូមបើកចិត្ត ហើយកុំកាត់សេចក្តីគេ ។ សូមស្វាគមន៍បុគ្គលគ្រប់រូប មិនថាបុគ្គលនោះស្ថិតនៅទីតាំងណាលើដំណើររបស់គាត់នោះទេ ។ សូមផ្តល់ជំនួយ ហើយផ្តោតលើសេចក្តីពិតថា បុគ្គលគ្រប់រូបគឺត្រូវការចាំបាច់នៅក្នុងសាសនាចក្រនេះ ។
- ប្រសិនបើអ្នកនិយាយអ្វីមួយដែលឈឺចាប់ដោយអចេតនា សូមកុំការពារសម្តីរបស់ខ្លួនឯងឡើយ ត្រូវសុំទោស រួចហើយសូមការអភ័យទោស និងកែលម្អ ។

សម្រាប់ព័ត៌មានអំពីការជួយដល់សមាជិកក្នុងស្ថានភាពជាក់លាក់នានា សូមមើលគេហទំព័រ **COUNSELINGRESOURCES.CHURCHOFJESUSCHRIST.ORG** ។

## វាមានប្រយោជន៍ដើម្បីនិយាយថា

- សូមស្វាគមន៍ ! យើងត្រូវការ និងស្រឡាញ់អ្នក ។ សូមអរគុណដែលបានមកទីនេះ ។
- សូមបង្រៀនខ្ញុំអំពីបទពិសោធន៍របស់អ្នក ។ តើអ្នកចង់ឲ្យខ្ញុំ យល់ពីអ្វីខ្លះ ?
- យើងស្វាគមន៍អ្នក ហើយយើងត្រូវការអ្នក មិនថាអ្នកនៅទីណាក្នុងដំណើររបស់អ្នកនោះទេ ។ តើយើងអាចជួយដោយរបៀបណា ? តើអ្នកអាចជួយយើងដោយរបៀបណា ?
- ព្រះទ្រង់សព្វព្រះទ័យឲ្យអ្នករីករាយនាពេលនេះ ។ ដំណឹងល្អរបស់ទ្រង់ផ្តល់សេចក្តីសង្ឃឹម និងសុភមង្គលដល់បុត្រាបុត្រីទាំងអស់របស់ទ្រង់ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ


© 2021 by Intellectual Reserve, Inc. All rights reserved. កំណែថ្មី៖ ៣/២១ ។ PD60012741 258. បោះពុម្ពនៅសហរដ្ឋអាមេរិក